ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥២៨ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលនីតិវិធីនៃការបំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីសម្រួលដល់ការនាំចេញទៅក្រៅប្រទេស ដូចខាងក្រោម÷

**ក-** ក្រុមហ៊ុន ឬ អ្នកនាំចេញដែលមានបំណងនាំចេញទំនិញពីព្រះរាជាណាចក្រកម្ពុជា ទោះបីជាស្ថិត ឬ មិនស្ថិតនៅក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មក៏ដោយ មិនតម្រូវឱ្យមកសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រសួងពាណិជ្ជកម្ម ឬ ការិយាល័យតំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសឡើយ ក្នុងករណីក្រុមហ៊ុន ឬ អ្នកនាំចេញពុំមានតម្រូវការ ឬ អាជ្ញាធរនៃប្រទេសនាំចូល មិនតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។

**ខ-** ក្រុមហ៊ុន ឬ អ្នកនាំចេញដូចបានបញ្ជាក់ក្នុងចំណុច ក ខាងលើ ត្រូវផ្ញើលិខិតជូនដំណឹងមកក្រសួងពាណិជ្ជកម្ម (តាមគំរូភ្ជាប់ជាឧបសម្ព័ន្ធ១ នៃប្រកាសអន្តរក្រសួងនេះ) តាមប្រព័ន្ធស្វ័យប្រវត្តកម្ម “ www.co.moc.gov.kh” ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃនាំចេញទំនិញ ដើម្បីក្រសួងពាណិជ្ជកម្មមានមូលដ្ឋានស្រង់ស្ថិតិ និងផ្ទៀងផ្ទាត់សន្និធិវត្ថុធាតុដើមនាំចូល។

**គ-** ក្នុងករណីក្រុមហ៊ុន ឬ អ្នកនាំចេញដែលមានបំណងនាំចេញទំនិញពីព្រះរាជាណាចក្រកម្ពុជា មានការចាំបាច់ត្រូវសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រសួងពាណិជ្ជកម្ម ឬ ការិយាល័យតំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ត្រូវបំពេញកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈដូចមានកំណត់ក្នុងប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម និងប្រកាសលេខ ៣១៩៨ ពណ.ខកល ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

**ប្រការ២ .-**

ចំពោះក្រុមហ៊ុន ឬ អ្នកនាំចេញដែលមានបំណងនាំចេញទំនិញគ្រប់ប្រភេទពីព្រះរាជាណាចក្រកម្ពុជាទៅកាន់សហភាពអឺរ៉ុប (EU) ស្ថិតក្រោមគម្រោង “ការអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់ លើកលែងគ្រឿងសព្វាវុធ (EBA)” រួមទាំងប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់ប្រទេសណ័រវេស, ប្រទេសស្វីស និងប្រទេសទួរគី ត្រូវចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ (Registered Exporter System - REX) របស់សហភាពអឺរ៉ុប ដើម្បីមាននីតិសម្បទាក្នុងការប្រកាសប្រភពដើម (Statement on Origin) ជំនួសឱ្យការប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញស្របតាមបទប្បញ្ញត្តិលេខ (EU) 2015/2447 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងលេខ (EU) 2017/989 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ របស់គណៈកម្មការអឺរ៉ុប។

លក្ខខណ្ឌតម្រូវសម្រាប់ចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញទៅកាន់សហភាពអឺរ៉ុប, ប្រទេសណ័រវេស, ប្រទេសស្វីស និងប្រទេសទួរគី មានដូចខាងក្រោម ÷

**ក- លក្ខណៈសម្បត្តិ**

ក្រុមហ៊ុន ឬ អ្នកនាំចេញក្រោមប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ÷

- មានមូលដ្ឋានផលិតកម្ម ឬ ទីតាំងស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា តែមិនមែនជាតំណាងអ្នកផ្តល់សេវាកម្រៃជើងសារគយ ឬ ពន្ធដារ
- ទំនិញនាំចេញបានអនុវត្តត្រឹមត្រូវតាមវិធានប្រភពដើមទំនិញរបស់សហភាពអឺរ៉ុប, ប្រទេសណ័រវេស, ប្រទេសស្វីស និងប្រទេសទួរគី
- មានចំណេះដឹង និងអាចប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា
- មិនស្ថិតក្នុងនីតិវិធីស្នើសុំក្ស័យធន
- មិនស្ថិតក្រោមការឃ្លាំមើល ឬ ស្ថិតក្នុងបញ្ជីខ្មៅរបស់ស្ថាប័នមានសមត្ថកិច្ច។

**ខ- ការស្នើសុំចុះបញ្ជីអ្នកនាំចេញ**

ដើម្បីចុះបញ្ជីក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ ក្រុមហ៊ុន ឬ អ្នកនាំចេញត្រូវដាក់ពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម÷

- ពាក្យស្នើសុំតាមគំរូភ្ជាប់ជាឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងនេះ ឬ អាចទាញយកពីគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម (www.moc.gov.kh)
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងវិញ្ញាបនបត្រចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងប័ណ្ណប៉ាតង់ (ច្បាប់ថតចម្លង)
- តារាងលម្អិតថ្លៃដើម ឬ ឯកសារអំណះអំណាងបញ្ជាក់ប្រភពដើមទំនិញនាំចេញ។

**គ- រយៈពេលបញ្ចប់នៃការចុះបញ្ជី**

- ក្រុមហ៊ុន ឬ អ្នកនាំចេញដែលបាន និងកំពុងនាំចេញទំនិញទៅសហភាពអឺរ៉ុប, ប្រទេសណ័រវេស, ប្រទេសស្វីស និងប្រទេសទួរគី ត្រូវមកចុះបញ្ជីក្នុងប្រព័ន្ធអ្នកនាំចេញ មិនឱ្យលើសកាលបរិច្ឆេទត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០
- ក្រុមហ៊ុន ឬ អ្នកនាំចេញដែលចាប់ផ្តើមប្រតិបត្តិការផលិតកម្ម ឬ នាំចេញក្រោយកាលបរិច្ឆេទកំណត់ខាងលើ អាចស្នើសុំចុះបញ្ជីក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ។

**ឃ- កម្រៃសម្រាប់ការចុះឈ្មោះក្នុងបញ្ជីអ្នកនាំចេញ**

ការចុះឈ្មោះក្នុងបញ្ជីអ្នកនាំចេញមិនតម្រូវឱ្យបង់ប្រាក់កម្រៃសេវាឡើយ។

**ង- ការលុបឈ្មោះចេញពីបញ្ជីអ្នកនាំចេញ**

ក្រុមហ៊ុន ឬ អ្នកនាំចេញនឹងត្រូវលុបឈ្មោះចេញពីបញ្ជីអ្នកនាំចេញ ក្នុងករណីដូចខាងក្រោម ÷

- មិនមានដំណើរការផលិតកម្ម ឬ ត្រូវបានប្រកាសបិទដោយអាជ្ញាធរមានសមត្ថកិច្ច
- ត្រូវបានរកឃើញថា មិនបានអនុវត្តតាមលក្ខខណ្ឌនៃវិធានប្រភពដើមទំនិញរបស់សហភាពអឺរ៉ុប ឬ ប្រទេសនាំចូល
- បានជូនដំណឹងអំពីការបញ្ឈប់ការនាំចេញតាមប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ

- ក្រុមហ៊ុនបានក្លែងបន្លំឯកសារទាក់ទងនឹងការនាំចេញ
- មានការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ចរបស់សហភាពអឺរ៉ុប ឬ ប្រទេសនាំចូល
- មិនបានអនុវត្តតាមលិខិតបទដ្ឋានច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ច- សិទ្ធិនៃការលុបឈ្មោះចេញពីបញ្ជីអ្នកនាំចេញ**

ការលុបឈ្មោះចេញពីបញ្ជីអ្នកនាំចេញត្រូវធ្វើឡើងតាមរយៈសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ផ្អែកតាមលក្ខខណ្ឌដែលមានចែងក្នុងចំណុច ង ខាងលើ។

**ប្រការ៣ ..**

ប្រកាសអន្តរក្រសួងលេខ ២៣៣ ពណ.បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសអន្តរក្រសួងនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ..**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ថ្ងៃសុក្រ ១០រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធស្រូវអង្ករកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ១

## ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ១៦២៧.. សហវ.ប្រក ចុះថ្ងៃទី២៨. ខែធ្នូ ឆ្នាំ២០១៨ ខែធ្នូ ឆ្នាំ២០១៨

## ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស

| 1. Exporter (name, full address, country) | Reference | |
|---|---|---|
| 2. Consignee (name, full address, country) | 4. Country of Origin | 5. Country of Destination |
| 3. Place and date of shipment - Means of transport | 6. Supplementary details | |

| 7. Marks and numbers | 8. Number and kind of packages, description of goods | 9. Quantity | 10. FOB Value US$ |
|---|---|---|---|
| | | | |

| 11. Certification | 12. Declaration by the exporter |
|---|---|
| It is hereby certified, on the basis of control carried out, that the declaration by the exporter is correct. | The undersigned hereby declares that the above details and statements are correct. |
| ........................................................................... | ........................................................................... |
| Place and date, signature and stamp of certifying authority | Place and date, signature and stamp of authorized signature |

ឧបសម្ព័ន្ធ២

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ១៩២៣.. សហវ.ប្រក ចុះថ្ងៃទី២៨. ខែធ្នូ ឆ្នាំ២០១៨ ខែធ្នូ ឆ្នាំ២០១៨

ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស

# APPLICATION FORM FOR THE GSP

APPLICATION TO BECOME A REGISTERED EXPORTER
for the purpose of schemes of generalised tariff preferences of the European Union, Norway, Switzerland and Turkey

| |
|---|
| 1. Exporter's name, full address and country, EORI or TIN(2). |
| 2. Contact details including telephone and fax number as well as e-mail address where available. |
| 3. Specify whether the main activity is producing or trading. |
| 4. Indicative description of goods which qualify for preferential treatment, including indicative list of Harmonised System headings (or chapters where goods traded fall within more than twenty Harmonised System headings). |

5. Undertakings to be given by an exporter

The undersigned hereby:

- declares that the above details are correct;
- certifies that no previous registration has been revoked; conversely, certifies that the situation which led to any such revocation has been remedied;
- undertakes to make out statements on origin only for goods which qualify for preferential treatment and comply with the origin rules specified for those goods in the Generalised System of Preferences;
- undertakes to maintain appropriate commercial accounting records for production / supply of goods qualifying for preferential treatment and to keep them for at least three years from the end of the calendar year in which the statement on origin was made out;
- undertakes to immediately notify the competent authority of changes as they arise to his registration data since acquiring the number of registered exporter;
- undertakes to cooperate with the competent authority;
- undertakes to accept any checks on the accuracy of his statements on origin, including verification of accounting records and visits to his premises by the European Commission or Member States' authorities, as well as the authorities of Norway, Switzerland and Turkey (applicable only to exporters in beneficiary countries);
- undertakes to request his removal from the system, should he no longer meet the conditions for exporting any goods under the scheme;
- undertakes to request his removal from the system, should he no longer intend to export such goods under the scheme.

_______________________________________

Place, date, signature of authorised signatory, name and job title

6. Prior specific and informed consent of exporter to the publication of his data on the public website

The undersigned is hereby informed that the information supplied in this application may be disclosed to the public via the public website. The undersigned accepts the publication and disclosure of this information via the public website. The undersigned may withdraw his consent to the publication of this information via the public website by sending a request to the competent authorities responsible for the registration.

……………………………………………………………………………………………..………

Place, date, signature of authorised signatory, name and job title

7. Box for official use by competent authority

The applicant is registered under the following number:

Registration Number: ……………………………………………………………………………………..

Date of registration ………………………………………………………..…..……………………

Date from which the registration is valid ………………………………...…………………………………

Signature and stamp ……………………………………………………………………………………

The present application form is common to the GSP schemes of four entities: the Union (EU), Norway, Switzerland and Turkey ('the entities'). Please note, however, that the respective GSP schemes of these entities may differ in terms of country and product coverage. Consequently, a given registration will only be effective for the purpose of exports under the GSP scheme(s) that consider(s) your country as a beneficiary country.

(2) The indication of EORI number is mandatory for EU exporters and reconsignors. For exporters in beneficiary countries, Norway, Switzerland and Turkey, the indication of TIN is mandatory.